# របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសលើកទី០៥ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. ថ្ងៃ ខែ ឆ្នាំ៖ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២

២. ទីកន្លែង៖ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

៣. ប្រធាន និងសមាសភាពចូលរួម ៖

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ និងតាមប្រព័ន្ធអនឡាញ សរុបចំនួន៧៤រូប។

៤. របៀបវារៈ៖ វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា

១. សង្ខេបស្ថានភាពជំងឺអេដស៍នៅកម្ពុជា

២. វឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅ៩៥-៩៥-៩៥

៣. វឌ្ឍនភាព និងសមិទ្ធផលនៃការថែទាំ និងព្យាបាលជំងឺអេដស៍

៤. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការ និងការធ្វើតេស្តរកមេរោគអេដស៍ ក្នុងចំណោមក្រុមប្រឈម

៥. បញ្ហាប្រឈម និងជំហានបន្ទាប់ដើម្បីឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ បង្ហាញដោយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

៥. លទ្ធផល ៖ តាមរបាយការណ៍សង្ខេបរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ អំពីស្ថានភាពជំងឺអេដស៍នៅកម្ពុជា កិច្ចប្រជុំបានសម្រេច និងឯកភាពមានដូចខាងក្រោម៖

៥.១ ឯកភាពទៅលើរបាយការណ៍សង្ខេបរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ស្តីពីវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅ៩៥-៩៥-៩៥

៥.២ ឯកភាពនៃការពន្យល់ក្នុងមាត្រាមួយចំនួនជាមួយច្បាប់ ជាពិសេសមាត្រាទី១៩ នៃច្បាប់អេដស៍ យកទៅដាក់ជាអាទិភាពមួយដែលជះឥទ្ធិពលដល់គោលដៅ ៩៥ ៩៥ ៩៥ ។ ចំពោះចំនុចនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងប្រជុំពិគ្រោះយោបល់ជាមួយនិងអង្គការ UNAIDS នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២។

៥.៣ ឯកភាពក្រុមបុរសស្រលាញ់បុរស និងក្រុមស្រីស្រស់មិនមែនជាប្រភពនៃការចម្លងមេរោគអេដស៍ ប៉ុន្តែឥរិយាបទរបស់ពួកគេប្រឈមនឹងការឆ្លងមេរោគអេដស៍ ដែលត្រូវយកចិត្តទុកដាក់។

៥.៤ ក្រុមការងារវេស្សរជនផ្ដើមថ្នាក់ជាតិ (កាកបាទក្រហមកម្ពុជា)

-ឯកភាពលើកបញ្ហាប្រឈម និងជំហ៊ានបន្ទាប់នឹងយកដាក់ឆ្លងក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២២

-ការពន្យល់មាត្រា១៩ នៃច្បាប់អេដស៍ដាក់ជាអាទិភាព និងពិភាក្សាកត្តារាំងដល់៩៥ ទីមួយ។

៥.៥ សហការគ្រប់ភាគីពាក់ព័ន្ធធ្វើយ៉ាងណាផ្ដល់សារឱ្យទូលំទូលាយ និងទូទាំងប្រទេស។

៦.កំណត់ប្រជុំខែក្រោយកំណត់យកថ្ងៃច័ន្ទ ៦រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ។

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

ស៊ុំ ផល្លា

**ប្រធានអង្គប្រជុំ**

**ឈឹម ឃិនដារ៉េត**